# ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ

## ថវិការបស់ឃុំ

## តើអ្នកបានដឹងអំពីថវិកាឃុំរបស់អ្នក ដែរឬទេ?

### ចំណូលរបស់ឃុំ

១

ចំណូលរបស់ឃុំអ្នក
បិទនៅត្រង់នេះ

### ចំណាយរបស់ឃុំ

២

ចំណាយរបស់ឃុំអ្នក
បិទនៅត្រង់នេះ

ប្រជាពលរដ្ឋ
ត្រូវ៖



ចូលរួមក្នុងការពិគ្រោះយោបល់
នៅភូមិរបស់អ្នក

ពិនិត្យ និងតាមដានចំណូល
និងចំណាយថវិកាឃុំ

ចូលរួមពិភាក្សាគម្រោង
អភិវឌ្ឍន៍ក្នុងឃុំរបស់អ្នក

ចូលរួមពិនិត្យ និងតាមដាន
ការអនុវត្តគម្រោង

## តើថវិកាឃុំរបស់អ្នកបានចំណាយដូចម្តេច?

បន្ទាប់ពីការស្តាប់ទស្សនៈរួមរបស់អ្នក តើឃុំសម្រេចចិត្តចំណាយថវិកាទាំងនេះសម្រាប់ធ្វើអ្វីខ្លះ?

៣

គម្រោងឃុំ
បិទបង្ហាញនៅទីនេះ



## សូមចូលរួមទាំងអស់គ្នា

អ្នកអាចជួយធ្វើឲ្យគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាឃុំ របស់អ្នកកាន់តែប្រសើរឡើង តាមរយៈការតាមដានការអនុវត្តគម្រោងនានា ដែលប្រើប្រាស់ថវិកាឃុំ

គ.ជ.អ.ប NCDD
គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍ
តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

ព័ត៌មានបន្ថែម សូមទាក់ទង
អ្នកសម្របសម្រួលគណនេយ្យភាពឃុំ ឬឃុំ

ក្រសួងមហាផ្ទៃ មហាវិថីនរោត្តម ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ: (៨៥៥) ២៣ ៧២០ ០៣៨, ៧២០ ០៦១
អ៊ីមែល: info@ncdd.gov.kh វេបសាយ: www.ncdd.gov.kh

# ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ

## ថវិការបស់ឃុំ

## តើអ្នកបានដឹងអំពីថវិកាឃុំរបស់អ្នក ដែរឬទេ?

### ចំណូលរបស់ឃុំ

១

ចំណូលរបស់ឃុំអ្នក
បិទនៅត្រង់នេះ

### ចំណាយរបស់ឃុំ

២

ចំណាយរបស់ឃុំអ្នក
បិទនៅត្រង់នេះ

ប្រជាពលរដ្ឋត្រូវៈ



ចូលរួមក្នុងការពិគ្រោះយោបល់នៅភូមិរបស់អ្នក

ពិនិត្យ និងតាមដានចំណូល និងចំណាយថវិកាឃុំ

ចូលរួមពិភាក្សាគម្រោងអភិវឌ្ឍន៍ក្នុងឃុំរបស់អ្នក

ចូលរួមពិនិត្យ និងតាមដានការអនុវត្តគម្រោង

## តើថវិកាឃុំរបស់អ្នកបានចំណាយដូចម្តេច?

បន្ទាប់ពីការស្តាប់ទស្សនៈរួមរបស់អ្នក តើឃុំសម្រេចចិត្តចំណាយថវិកាទាំងនេះសម្រាប់ធ្វើអ្វីខ្លះ?

៣

គម្រោងឃុំ
បិទបង្ហាញនៅទីនេះ



## សូមចូលរួមទាំងអស់គ្នា

អ្នកអាចជួយធ្វើឲ្យគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាឃុំ របស់អ្នកកាន់តែប្រសើរឡើង តាមរយៈការតាមដានការអនុវត្តគម្រោងនានា ដែលប្រើប្រាស់ថវិកាឃុំ

គ.ជ.អ.ប
NCDD
គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

ព័ត៌មានបន្ថែម សូមទាក់ទង
អ្នកសម្របសម្រួលគណនេយ្យភាពឃុំ ឬឃុំ

ក្រសួងមហាផ្ទៃ មហាវិថីនរោត្តម ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ: (៨៥៥) ២៣ ៧២០ ០៣៨, ៧២០ ០៦១
អ៊ីម៉ែល: info@ncdd.gov.kh វេបសាយ: www.ncdd.gov.kh

# ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ

## ការបំពេញតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ

### តើអ្នកដឹងទេថាក្រុមប្រឹក្សាឃុំបំពេញតួនាទី ភារកិច្ចអ្វីខ្លះ?



១ ភាពជាតំណាង និង ការធ្វើសេចក្ដីសម្រេចចិត្ត



២ ការចុះបញ្ជីអត្រានុកូលដ្ឋាន



៣ ការកសាងផែនការ និងថវិកា

### តើការបំពេញតួនាទី ភារកិច្ចក្រុមប្រឹក្សាឃុំយ៉ាងដូចម្ដេចដែរ?

ត្រួតពិនិត្យមើលការបំពេញការងារឃុំរបស់អ្នក







១

ការងាររបស់ឃុំអ្នក
បិទបង្ហាញនៅទីនេះ

២

ការងាររបស់ឃុំអ្នក
បិទបង្ហាញនៅទីនេះ









### បិទផ្សាយព័ត៌មានរបស់ឃុំជាសាធារណៈ

ការបិទផ្សាយជាសាធារណៈនូវផែនការអភិវឌ្ឍន៍ឃុំ ផែនការថវិកាឃុំ និងការចំណាយទាំងអស់របស់ឃុំ


គជអប NCDD
គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍ
តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

ព័ត៌មានបន្ថែម សូមទាក់ទង
អ្នកសម្របសម្រួលគណនេយ្យភាពឃុំ ឬមេឃុំ

ក្រសួងមហាផ្ទៃ មហាវិថីនរោត្តម ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ: (៨៥៥) ២៣ ៧២០ ០៣៨, ៧២០ ០៦១
អ៊ីម៉ែល: info@ncdd.gov.kh គេហទំព័រ: www.ncdd.gov.kh

# ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ

## សិទ្ធិរបស់អ្នកនៅឃុំ

### តើអ្នកដឹងទេ?



**ក្រុមប្រឹក្សាឃុំរបស់អ្នកត្រូវបានបោះឆ្នោតជ្រើសរើសឡើង ដោយខ្លួនអ្នកផ្ទាល់ ក្នុងមួយអាណត្តិ មានរយៈពេល ៥ឆ្នាំម្តង**

- អ្នកត្រូវទៅចូលរួមបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ នៅរៀងរាល់៥ឆ្នាំម្តង ដើម្បីធ្វើជាតំណាងក្នុងឃុំរបស់អ្នក



**ក្រុមប្រឹក្សាឃុំត្រូវស្តាប់មតិ យោបល់របស់អ្នក**

- ក្រុមប្រឹក្សាឃុំត្រូវរៀបចំកិច្ចប្រជុំជាមួយភូមិរៀងរាល់ខែ និងប្រចាំឆ្នាំ ដើម្បីស្តាប់មតិ យោបល់អ្នក អំពីការប្រើប្រាស់ថវិកាឃុំ



**ក្រុមប្រឹក្សាឃុំត្រូវអញ្ជើញអ្នកឲ្យចូលរួមប្រជុំ**

- ដើម្បីស្តាប់ការធ្វើសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាឃុំ
- ក្រុមប្រឹក្សាឃុំ ត្រូវតែជូនដំណឹង និងបិទផ្សាយជាសាធារណៈ អំពីកាលបរិច្ឆេទកិច្ចប្រជុំ របៀបវារៈ ប្រធានបទ និងកំណត់ហេតុកិច្ចប្រជុំ នៅលើក្តារព័ត៌មានឃុំ



**អ្នកអាចចូលរួមប្រជុំជាមួយក្រុមប្រឹក្សាឃុំ មានសិទ្ធិផ្តល់យោបល់ និងសួរសំណួរ អំពីការផ្តល់សេវា និងគម្រោងនានា**

- អ្នកអាចធ្វើការទំនាក់ទំនងជាមួយក្រុមប្រឹក្សាឃុំឲ្យជួយដោះស្រាយបញ្ហា តម្រូវការ ឆ្លើយតបចំពោះបណ្តឹងតវ៉ា ឆ្លើយតបទៅនឹងសំណួរនានា អំពីសេវាកម្មឃុំ និងគម្រោងអភិវឌ្ឍន៍ឃុំ
- ក្រុមប្រឹក្សាឃុំត្រូវបង្ហាញ និងប្រាប់អ្នកអំពីថវិកា ផែនការ សកម្មភាព និងគម្រោងអភិវឌ្ឍន៍ឃុំ នៅក្នុងកិច្ចប្រជុំ



**ការផ្តល់សំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ និងសំបុត្រមរណភាព**

- អ្នកត្រូវទទួលបានសំបុត្រកំណើត សំបុត្របញ្ជាក់កំណើត សំបុត្រអាពាហ៍ពិពាហ៍ ឬសំបុត្រមរណភាព ពីសាលាឃុំ បន្ទាប់ពីបានដាក់ពាក្យស្នើសុំក្នុងរយៈពេល៣ថ្ងៃនៃថ្ងៃធ្វើការ (ប្រសិនបើមានឯកសារភ្ជាប់គ្រប់គ្រាន់)
- ក្រុមប្រឹក្សាឃុំត្រូវផ្តល់សេវាដោយស្មើភាពគ្នា មិនត្រូវរើសអើង ឬប្រកាន់បក្សពួក
- រដ្ឋបាលឃុំមិនត្រូវយកតម្លៃសេវាលើសពីតារាងតម្លៃសេវា ដែលបានកំណត់ដោយលិខិតបទដ្ឋាន ស្របតាមផ្លូវច្បាប់



**ការបិទផ្សាយព័ត៌មាន**

- ក្រុមប្រឹក្សាឃុំត្រូវបិទផ្សាយព័ត៌មានជាសាធារណៈ អំពីផែនការការងារ ថវិកា គម្រោងអភិវឌ្ឍន៍ ម៉ោងធ្វើការ តារាងតម្លៃសេវាឃុំ និងរបាយការណ៍នានារបស់ឃុំ

**សូមចូលរួម** ជួយកែលម្អការផ្តល់សេវាឃុំរបស់អ្នក


គជអប NCDD
គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

ព័ត៌មានបន្ថែម សូមទាក់ទង
អ្នកសម្របសម្រួលគណនេយ្យភាពឃុំ ឬមេឃុំ

ក្រសួងមហាផ្ទៃ មហាវិថីនរោត្តម ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ: (៨៥៥) ២៣ ៧២០ ០៣៨, ៧២០ ០៦១
អ៊ីម៉ែល: info@ncdd.gov.kh វេបសាយ: www.ncdd.gov.kh

# ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ

## ថវិកា និងការងាររបស់មណ្ឌលសុខភាព

### តើអ្នកបានដឹងអំពីថវិការបស់មណ្ឌលសុខភាពអ្នកដែរឬទេ?

**ចំណូលរបស់មណ្ឌលសុខភាព**

១

ចំណូលក្នុងមណ្ឌលសុខភាព
បិទបង្ហាញក្នុងប្រអប់នេះ

**ចំណាយរបស់មណ្ឌលសុខភាព**

២

ចំណាយក្នុងមណ្ឌលសុខភាព
បិទបង្ហាញក្នុងប្រអប់នេះ

### តើមណ្ឌលសុខភាពរបស់អ្នកបំពេញការងារយ៉ាងដូចម្តេចដែរ?

**ពិនិត្យមើលការបំពេញការងារមណ្ឌលសុខភាពរបស់អ្នក**







៣

លទ្ធផលការបំពេញការងារ
របស់មណ្ឌលសុខភាពអ្នក
បិទបង្ហាញនៅទីនេះ

៤

លទ្ធផលការបំពេញការងារ
របស់មណ្ឌលសុខភាពអ្នក
បិទបង្ហាញនៅទីនេះ









### បិទផ្សាយព័ត៌មានអំពីសេវាសុខភាពទាំងអស់

អាចផ្តល់ព័ត៌មានដល់អ្នក និងជួយពន្យល់អ្នកឲ្យបានយល់អំពីសេវានានា ពេលម៉ោងធ្វើការ តម្លៃសេវា និងសេវាដែលមិនបង់ថ្លៃ


គ.ជ.អ.ប NCDD

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍ
តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

ព័ត៌មានបន្ថែម សូមទាក់ទងអ្នកសម្របសម្រួល
គណនេយ្យករឃុំ ប្រធានមណ្ឌលសុខភាព ឬមេឃុំ

ក្រសួងមហាផ្ទៃ មហាវិថីនរោត្តម ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ: (៨៥៥) ២៣ ៧២០ ០៣៨, ៧២០ ០៦១
អ៊ីម៉ែល: info@ncdd.gov.kh វេបសាយ: www.ncdd.gov.kh

# ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ

# សិទ្ធិរបស់អ្នកនៅមណ្ឌលសុខភាព

## តើអ្នកដឹងទេ?



### បុគ្គលិកមណ្ឌលសុខភាពនឹងផ្តល់សេវាជូនអ្នកដោយស្មើភាពគ្នា និងរួសរាយរាក់ទាក់

- បុគ្គលិកមណ្ឌលសុខភាពនឹងផ្តល់សេវាជូនអ្នកនូវការថែទាំសុខភាពដ៏ល្អប្រសើរ មានប្រសិទ្ធភាព ប្រកបដោយសេចក្តីថ្លៃថ្នូរ និងរួសរាយរាក់ទាក់ មិនមានការរើសអើង



### បុគ្គលិកមណ្ឌលសុខភាពនឹងបង្ហាញជូនព័ត៌មានអំពីសេវាសុខភាពទាំងអស់

- បុគ្គលិកមណ្ឌលសុខភាពត្រូវជម្រាបជូនអ្នកច្បាស់លាស់អំពីពេលវេលា ប្រភេទសេវា តម្លៃសេវាទាំងអស់ និងសេវានានាណាដែលមិនត្រូវបង់ថ្លៃ



### បុគ្គលិកមណ្ឌលសុខភាពនឹងជួយពន្យល់ណែនាំអំពីបញ្ហាសុខភាពរបស់អ្នក

- បុគ្គលិកមណ្ឌលសុខភាពនឹងជួយពន្យល់ណែនាំអ្នកឲ្យយល់អំពីស្ថានភាពជំងឺ និងបញ្ហាសុខភាពរបស់អ្នក ដោយការយកចិត្តទុកដាក់ និងប្រើភាសាសាមញ្ញងាយយល់
- បុគ្គលិកមណ្ឌលសុខភាពត្រូវរក្សាការសម្ងាត់ទាំងអស់អំពីសុខភាពរបស់អ្នក ឲ្យបានយ៉ាងត្រឹមត្រូវ



### បុគ្គលិកមណ្ឌលសុខភាពត្រូវឲ្យអ្នកបង់ប្រាក់ទៅតាមតារាងតម្លៃសេវា

- បុគ្គលិកមណ្ឌលសុខភាពនឹងប្រាប់អ្នកអំពីតម្លៃសេវា និងរបៀបបង់ថ្លៃសេវា ប្រសិនបើអ្នកត្រូវការបង់ប្រាក់
- បុគ្គលិកមណ្ឌលសុខភាពមិនត្រូវទាមទារ ឬទទួលប្រាក់បន្ថែម ទោះបីអ្នកជំងឺផ្តល់ជូនក៏ដោយ



### បុគ្គលិកមណ្ឌលសុខភាពត្រូវធានារក្សាការសម្ងាត់ ( បុគ្គលភាព ) ជាពិសេសស្ត្រី

- បុគ្គលិកមណ្ឌលសុខភាពត្រូវធានារក្សាការសម្ងាត់អំពីស្ថានភាពជំងឺរបស់អ្នក ដោយធ្វើការពិនិត្យព្យាបាល និងថែទាំជំងឺ នៅក្នុងបន្ទប់ផ្សេងគ្នារវាងបុរស និងស្ត្រី និងមានបង្គន់អនាម័យផងដែរ



### បុគ្គលិកមណ្ឌលសុខភាពត្រូវពន្យល់អំពីវិធីព្យាបាលជំងឺ និងសុំការយល់ព្រមពីអ្នក និងទទួលយកមតិយោបល់ពីអ្នកក្រោយពីការព្យាបាលជំងឺ

- បុគ្គលិកមណ្ឌលសុខភាពត្រូវសុំការយល់ព្រម និងពិគ្រោះយោបល់ចំពោះការពិនិត្យព្យាបាលជំងឺ និងទទួលយកមតិ យោបល់ត្រឡប់ពីអ្នក

## សូមចូលរួម ជួយកែលម្អមណ្ឌលសុខភាពរបស់អ្នក

គជអប NCDD
គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

ព័ត៌មានបន្ថែម សូមទាក់ទងអ្នកសម្របសម្រួល
គណៈគ្រប់គ្រងមណ្ឌលសុខភាព ប្រធានមណ្ឌលសុខភាព ឬមេឃុំ

ក្រសួងមហាផ្ទៃ មហាវិថីនរោត្តម ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ: (៨៥៥) ២៣ ៧២០ ០៣៨, ៧២០ ០៦១
អ៊ីមែល: info@ncdd.gov.kh គេហទំព័រ: www.ncdd.gov.kh

# ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ

# ស្តង់ដាមណ្ឌលសុខភាព

## តើអ្នកដឹងអ្វីខ្លះនៅមណ្ឌលសុខភាព?



### មណ្ឌលសុខភាពរបស់អ្នកត្រូវមានបុគ្គលិកធ្វើការពី៨-១១នាក់

- មណ្ឌលសុខភាពត្រូវមានបុគ្គលិកពី៨នាក់ ទៅ១១នាក់ បំពេញការងារក្នុងម៉ោងធ្វើការ នៅរង់ចាំផ្តល់សេវាជូនអ្នកគ្រប់ពេលវេលា



### មណ្ឌលសុខភាពរបស់អ្នកត្រូវមានបុគ្គលិកប្រចាំការ ២៤ម៉ោង

- មណ្ឌលសុខភាពត្រូវមានបុគ្គលិកប្រចាំការ២៤ម៉ោង សម្រាប់សង្គ្រោះបន្ទាន់ និងត្រូវមានកាលវិភាគវេនយាមប្រចាំការ និងព័ត៌មានសម្រាប់ទំនាក់ទំនង



### មណ្ឌលសុខភាពអ្នកត្រូវទទួលបានការផ្គត់ផ្គង់ឱសថចំនួន១២ដងក្នុង១ឆ្នាំ

- មណ្ឌលសុខភាពត្រូវទទួលបានការផ្គត់ផ្គង់ឱសថព្យាបាលជំងឺ និងសម្ភារបរិក្ខា ជារៀងរាល់ខែ ដែលមានចំនួន១២ដង ក្នុង១ឆ្នាំ ពីការិយាល័យស្រុកប្រតិបត្តិ
- មណ្ឌលសុខភាពត្រូវផ្តល់ឱសថពេទ្យតាមវេជ្ជបញ្ជាជូនអ្នក ទៅតាមប្រភេទជំងឺ ឲ្យបានត្រឹមត្រូវ



### មណ្ឌលសុខភាពអ្នកត្រូវមានបង្គន់អនាម័យដាច់ដោយឡែកពីគ្នា

- មណ្ឌលសុខភាពត្រូវមានបង្គន់អនាម័យ ២ទៅ៣បន្ទប់ ដាច់ដោយឡែកពីគ្នា សម្រាប់បុរស ស្ត្រី និងជនពិការ (បង្គន់អនាម័យទាំងនោះអាចដំណើរការ និងប្រើប្រាស់បានជាប្រចាំ)



### គណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាពត្រូវប្រជុំ១២ដង ក្នុង១ឆ្នាំ

- គណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាពត្រូវប្រជុំ១ដង ក្នុង១ខែ ដើម្បីពិភាក្សា និងដោះស្រាយបញ្ហា ដែលពាក់ព័ន្ធនឹងការផ្តល់សេវាសុខភាពជូនប្រជាពលរដ្ឋ



### មណ្ឌលសុខភាពអ្នកត្រូវបិទផ្សាយព័ត៌មានជាសាធារណៈ

- មណ្ឌលសុខភាព ត្រូវបិទផ្សាយព័ត៌មានជាសាធារណៈ អំពីប្រភេទសេវា តម្លៃសេវា ម៉ោងធ្វើការ កាលវិភាគវេនប្រចាំការ២៤ម៉ោង និងព័ត៌មានសម្រាប់ទំនាក់ទំនង

## សូមចូលរួម ជួយកែលម្អមណ្ឌលសុខភាពរបស់អ្នក

គជអប NCDD គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

ព័ត៌មានបន្ថែម សូមទាក់ទងអ្នកសម្របសម្រួលគណនេយ្យភាពឃុំ ប្រធានមណ្ឌលសុខភាព ឬមេឃុំ

ក្រសួងមហាផ្ទៃ មហាវិថីនរោត្តម ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ: (៨៥៥) ២៣ ៧២០ ០៣៨, ៧២០ ០៦១
អ៊ីមែល: info@ncdd.gov.kh វេបសាយ: www.ncdd.gov.kh

# ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ

# ផែនការសកម្មភាពគណនេយ្យភាពរួម

## តើអ្នកបានដឹងពីផែនការសកម្មភាពរួមនេះ ដែរឬទេ?







១

បិទបង្ហាញ
ផែនការសកម្មភាពគណនេយ្យភាពរួម
នៅត្រង់នេះ









**សូមចូលរួមទាំងអស់គ្នា**

អ្នកអាចជួយកែលម្អគុណភាពសេវាឃុំរបស់អ្នក ដោយចូលរួម
រៀបចំផែនការសកម្មភាពគណនេយ្យភាពរួម

គជអប
NCDD
គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍ
តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

ព័ត៌មានបន្ថែម សូមទាក់ទង
អ្នកសម្របសម្រួលគណនេយ្យភាពឃុំ ឬមេឃុំ

ក្រសួងមហាផ្ទៃ មហាវិថីនរោត្តម ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ: (៨៥៥) ២៣ ៧២០ ០៣៨, ៧២០ ០៦១
អ៊ីមែល: info@ncdd.gov.kh វេបសាយ: www.ncdd.gov.kh

# ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ
# សិទ្ធិរបស់អ្នកនៅសាលារៀន

## តើអ្នកដឹងអ្វីខ្លះអំពីសាលារៀន?



### កុមារមានអាយុចាប់ពី ៦ឆ្នាំឡើង ត្រូវចុះឈ្មោះចូលរៀននៅថ្នាក់ទី១ និងបន្តការសិក្សារហូតដល់ចប់ថ្នាក់ទី៩ដោយឥតបង់ថ្លៃ

- មាតា បិតា អាណាព្យាបាល ដែលមានកូនគ្រប់អាយុ៦ឆ្នាំ ឬយ៉ាងតិច៧០ខែ ត្រូវនាំកូនៗទៅចុះឈ្មោះចូលរៀនឲ្យបានគ្រប់ៗគ្នា
- លោកគ្រូ អ្នកគ្រូបង្រៀនសិស្សានុសិស្សដោយស្មើភាពគ្នា មិនប្រកាន់វណ្ណៈ ពណ៌សម្បុរ ពូជសាសន៍ និងមិនរើសអើង



### សាលារៀនត្រូវមានគ្រូម្នាក់សម្រាប់សិស្សមិនលើសពី៤២នាក់ ក្នុង ១ ថ្នាក់

- ថ្នាក់រៀនមួយ ត្រូវមានគ្រូម្នាក់សម្រាប់សិស្ស ៤២ នាក់យ៉ាងច្រើន




### គ្រូត្រូវបង្រៀនឲ្យបាន ២២៨ ថ្ងៃ ក្នុង ១ ឆ្នាំ

- គ្រូត្រូវបង្រៀនសិស្សឲ្យបាន១៩០ថ្ងៃ តាមកម្មវិធីជាតិ និង៣៨ថ្ងៃអំពីបំណិនជីវិត ជារៀងរាល់ឆ្នាំ
- គ្រូបង្រៀនត្រូវមានវត្តមាននៅក្នុងថ្នាក់រៀន រាល់ម៉ោងបង្រៀន



### សាលារៀនត្រូវមានសៀវភៅពុម្ពឲ្យសិស្សខ្ចីចំនួន ៣ ទៅ ៤ ក្បាល ដោយឥតបង់ថ្លៃ

- សាលារៀនត្រូវឲ្យសិស្សម្នាក់ៗខ្ចីសៀវភៅពុម្ព ៣ ក្បាល សម្រាប់សិស្សថ្នាក់ទី ១ ដល់ថ្នាក់ទី ៣ និង ៤ ក្បាលសម្រាប់សិស្សថ្នាក់ទី ៤ ដល់ថ្នាក់ទី ៦



### សាលារៀនត្រូវមានបង្គន់អនាម័យសម្រាប់សិស្សស្រី និងសិស្សប្រុស

- សាលារៀននីមួយៗត្រូវមានបង្គន់អនាម័យ ដែលដំណើរការល្អ ប្រើប្រាស់បានគ្រប់ពេលវេលា និង ទីស្នាដាច់ដោយឡែកពីគ្នាសម្រាប់សិស្សស្រី និងសិស្សប្រុស



### លោកគ្រូ អ្នកគ្រូ ត្រូវជួយសិស្សក្នុងការរៀនសូត្រ

- គ្រូត្រូវស្រលាញ់សិស្សឲ្យស្មើភាពគ្នា
- គ្រូត្រូវផ្តល់ក្តីគោរពស្មើៗគ្នាចំពោះសិស្ស
- គ្រូមិនត្រូវឲ្យសិស្សបង់ប្រាក់ក្រៅផ្លូវការ
- គ្រូមិនត្រូវធ្វើទារុណកម្មលើរាងកាយ ឬលើផ្លូវចិត្តសិស្ស
- លោកគ្រូ អ្នកគ្រូ ត្រូវផ្តល់ព័ត៌មាន អំពីលទ្ធផលនៃការសិក្សារបស់សិស្សដល់ឪពុកម្តាយ ឬអាណាព្យាបាលសិស្ស តាមការស្នើសុំ

## សូមចូលរួម ជួយកែលម្អសាលារៀនអ្នក


គជអម NCDD គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

ព័ត៌មានបន្ថែម សូមទាក់ទងអ្នកសម្របសម្រួល គណនេយ្យភាពឃុំ មេឃុំ ឬនាយកសាលា

ក្រសួងមហាផ្ទៃ មហាវិថីនរោត្តម ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ: (៨៥៥) ២៣ ៧២០ ០៣៨, ៧២០ ០៦១
អ៊ីម៉ែល: info@ncdd.gov.kh វេបសាយ: www.ncdd.gov.kh

# ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ

## ថវិកា និងការបំពេញការងាររបស់សាលាបឋមសិក្សា

### តើអ្នកបានដឹងអំពីថវិការបស់សាលារៀនដែរឬទេ?

ចំណូលក្នុងសាលារៀន

ចំណាយក្នុងសាលារៀន

១

ចំណូលក្នុងសាលារៀន
បិទបង្ហាញត្រង់នេះ

២

ចំណាយក្នុងសាលារៀន
បិទបង្ហាញត្រង់នេះ

### តើសាលារៀនរបស់អ្នកបំពេញការងារយ៉ាងដូចម្តេច?

ពិនិត្យអំពីការបំពេញការងាររបស់សាលារៀន





៣

ការបំពេញការងាររបស់
សាលារៀន
បិទបង្ហាញនៅទីនេះ

៤

ការបំពេញការងាររបស់
សាលារៀន
បិទបង្ហាញនៅទីនេះ







### បិទផ្សាយរាល់ព័ត៌មានរបស់សាលារៀន

បិទបង្ហាញជាសាធារណៈពីផែនការអភិវឌ្ឍន៍សាលារៀន ផែនការថវិកាសាលា និងការចំណាយទាំងអស់


គជអប
NCDD
គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍ
តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

ព័ត៌មានបន្ថែម សូមទាក់ទងអ្នកសម្របសម្រួល
គណនេយ្យភាពឃុំ នាយកសាលា ឬមេឃុំ

ក្រសួងមហាផ្ទៃ មហាវិថីនរោត្តម ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ: (៨៥៥) ២៣ ៧២០ ០៣៨, ៧២០ ០៦១
អ៊ីមែល: info@ncdd.gov.kh វិបសាយ: www.ncdd.gov.kh